មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោក

**រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣**

ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ ជាទិវាសេរីភាពសារព័ត៌មានពិភពលោក។ ទិវានេះប្រារព្ធឡើងដើម្បីគោរពដល់តួនាទីដ៏សំខាន់របស់អ្នកសារព័ត៌មានក្នុងការផ្តល់ព័ត៌មានត្រឹមត្រូវ និងអាចទុកចិត្តបានដល់សាធារណជន ដែលពេលខ្លះអ្នកសារព័ត៌មានក៏ប្រឈមនឹងបញ្ហាអាយុជីវិតរបស់ខ្លួនផងដែរ។ ទិវានេះក៏ជាការរំលឹកឡើងវិញនូវសារៈសំខាន់នៃសេរីភាពសារព័ត៌មានក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងប្រជាធិបតេយ្យ និងជាការរំលឹកដល់រដ្ឋាភិបាលនៅជុំវិញពិភពលោកឱ្យបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការលើកកម្ពស់ និងគោរពសេរីភាពសារព័ត៌មាន ព្រមទាំងបង្កបរិយាកាសឱ្យមានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយសេរី និងរស់រវើក។

ជាការគួរឱ្យសោកស្តាយ ម.ស.ម.ក សង្កេតឃើញថាប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យនៅកម្ពុជានៅតែបន្តប្រឈមនឹងឧបសគ្គជាច្រើនក្នុងការបំពេញការងារស្របតាមវិជ្ជាជីវៈរបស់ខ្លួនដោយសេរី និងគ្មានការដាក់កំហិតសិទ្ធិរបស់ខ្លួនឯង។ ការធ្វើទុក្ខបុកម្នេញ និងបន្តដៅមុខសញ្ញាទៅលើប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានឯករាជ្យក្នុងការអនុវត្តសិទ្ធិមូលដ្ឋានរបស់ខ្លួនចំពោះសេរីភាពខាងការបញ្ចេញមតិនៅតែបន្តកើតមាននៅក្នុងសង្គមកម្ពុជា។ ការវាយប្រហារលើរាងកាយទៅលើអ្នកសារព័ត៌មាន ឃាតកម្ម ការដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងការយាយីតាមប្រព័ន្ធតុលាការ នៅតែជាវិធីសាស្ត្រក្នុងការប្រើដើម្បីបំបិទមតិរិះគន់។

នៅចន្លោះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ អ្នកសារព័ត៌មាន ២០ នាក់ត្រូវបានយាយីតាមប្រព័ន្ធតុលាការដោយសារតែការរាយការណ៍ព័ត៌មានរបស់ខ្លួន ខណៈអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួន ៤ ត្រូវបានដកហូត។ រហូតមកដល់ពេលនេះអាជ្ញាធរកម្ពុជានៅតែខកខានក្នុងការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាពចំពោះករណីស្លាប់របស់អ្នកសារព័ត៌មានទាំង ១៥ រូបដែលត្រូវបានសម្លាប់ក្នុងអំឡុងពេលពីរទសវត្សចុងក្រោយនេះ ហើយជនល្មើសនូវមិនទាន់ត្រូវបានកាត់ទោសឱ្យសមស្របតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិនៅឡើយទេ។

នៅក្នុងបរិបទនៃការបន្តធ្លាក់ចុះនៃបរិយាកាសសារព័ត៌មាននៅកម្ពុជា ទិវានេះក៏មានសារៈសំខាន់ក្នុងការរំលឹកផងដែរថាបើគ្មានប្រព័ន្ធផ្សព្វផ្សាយសេរី និងឯករាជ្យនោះទេ លទ្ធិប្រជាធិបតេយ្យក៏មិនអាចរីកចម្រើនផងដែរ។

ដើម្បីប្រារព្ធទិវាសេរីភាពសារព័ត៌មានពិភពលោកនៅឆ្នាំនេះ ម.ស.ម.ក នឹងរៀបចំកម្មវិធី យុទ្ធនាការនៅការិយាល័យ និងតាមអ៊ីនធឺណិតជាបន្តបន្ទាប់ដែលមានគោលបំណងអប់រំសាធារណជនអំពីទិវានេះ និងពីសេរី

ភាពខាងការបញ្ចេញមតិ ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅក្នុងសង្គមប្រជាធិបតេយ្យ។ សូមចូលរួមជាមួយ ម.ស.ម.ក សម្រាប់ព្រឹត្តិការណ៍ដូចខាងក្រោម៖

- នៅថ្ងៃទី២៧ ខែមេសា ម.ស.ម.ក នឹងរៀបចំកម្មវិធីបង្ហាញអំពីជីវប្រវត្តិរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ១៥ រូប និងផ្តល់រង្វាន់ចំពោះគំនិតផ្តួចផ្តើមគម្រោងរបស់យុវជនអំពីសិទ្ធិមនុស្ស។
- ចាប់ពីថ្ងៃទី២៨ ខែមេសា ដល់ថ្ងៃទី១២ ខែឧសភា ម.ស.ម.ក នឹងចេញផ្សាយជីវប្រវត្តិរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សទាំង ១៥ រូប និងវីដេអូខ្លីៗចំនួន១៥ នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។
- នៅថ្ងៃទី១ និងថ្ងៃទី២ ខែឧសភា ម.ស.ម.ក នឹងចាក់ផ្សាយឡើងវិញនូវវីដេអូជីវចលដែលបង្ហាញអំពីសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។
- នៅថ្ងៃទី៣ ខែឧសភា ម.ស.ម.ក នឹងរៀបចំកម្មវិធីវិទ្យុដែលនឹងជជែកអំពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងសង្គមប្រជាធិបតេយ្យ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក ហួន ផន អ្នកសម្របសម្រួលគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា នៃម.ស.ម.ក តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬ ០៧០ ៧៥៧ ៨៨៤៕

<u>ចប់</u>

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការលើកកម្ពស់ និងការពារសិទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។